**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសរួម
# ស្តីពីទស្សនកិច្ចផ្លូវការរបស់លោកជំទាវ សេក្ខ ហាស៊ីណា នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស នៅព្រះរាជាណាចក្រកម្ពុជា
# ភ្នំពេញ ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ ២០១៧

តាមការអញ្ជើញរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវ សេក្ខ ហាស៊ីណា នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ០៣ ដល់ ០៥ ខែធ្នូ ឆ្នាំ២០១៧។

លោកជំទាវនាយករដ្ឋមន្ត្រីបង់ក្លាដែស បានអញ្ជើញទៅដាក់កម្រងផ្កា នៅស្តូបវិមានឯករាជ្យ និងគោរពវិញ្ញាណក្ខន្ធវីរបុរស និងវីរនារីកម្ពុជា ដែលបានពលីក្នុងសង្គ្រាម។ លោកជំទាវនាយករដ្ឋមន្ត្រី បានអញ្ជើញទៅគោរពព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រកម្ពុជា ព្រះករុណា ព្រះបាទ សម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។ លោកជំទាវ សេក្ខ ហាស៊ីណា ក៏បានអញ្ជើញទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ផងដែរ។

លោកជំទាវនាយករដ្ឋមន្ត្រីបង់ក្លាដែស បានទទួលព្រះរាជានុញ្ញាតឲ្យចូលក្រាបបង្គំគាល់ ព្រះករុណា ព្រះបាទ សម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃកម្ពុជា។ ព្រះករុណា បានរំលឹកអំពីសម្ព័ន្ធភាពជិតស្និទ្ធពិសេស របស់អតីតព្រះមហាក្សត្រកម្ពុជា ចំពោះបិតាជាតិរបស់បង់ក្លាដែស បង់ហ្គាបាន់ឌូ សេក្ខ មូជីប៊ូរ៉ាម៉ាន់ ព្រមទាំងអរគុណចំពោះការកោតសរសើររបស់ប្រជាជនបង់ក្លាដែស ចំពោះអតីតព្រះមហាក្សត្រកម្ពុជា នរោត្តម សីហនុ។ ក្នុងន័យនេះ ព្រះអង្គ បានស្វាគមន៍ការប្រកាសរបស់នាយករដ្ឋមន្ត្រីប្រទេសទាំងពីរ អំពីការដាក់ឈ្មោះផ្លូវសំខាន់មួយនៃប្រទេសរៀងខ្លួន ក្នុងរាជធានីភ្នំពេញ និងរដ្ឋធានីដាកា ដើម្បីជានិមិត្តរូបនៃការគោរពថ្នាក់ដឹកនាំដ៏ឆ្នើមទាំងពីរ។

នៅក្នុងការចរចាផ្លូវការ នាថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៧ ក្នុងបរិយាកាសមិត្តភាព និងការយោគយល់គ្នាទៅវិញទៅមក នាយករដ្ឋមន្ត្រីទាំងពីរ បានពិភាក្សាគ្នាយ៉ាងស៊ីជម្រៅលើបញ្ហាជាច្រើនដ៏ទូលំទូលាយ ក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងពហុភាគី ដែលជាផលប្រយោជន៍ទៅវិញទៅមក។ ថ្នាក់ដឹកនាំទាំងពីរ បានអះអាងជាថ្មីនូវការប្តេជ្ញាធ្វើឲ្យកាន់តែស៊ីជម្រៅនូវទំនាក់ទំនងទ្វេភាគីរវាង កម្ពុជា និង បង់ក្លាដែស ដែលមានឬសគល់យ៉ាងជ្រៅក្នុងកេរដំណែលរួមនៃប្រវត្តិសាស្រ្ត សាសនា វប្បធម៌ និងអក្សរសាស្រ្ត នៃប្រជាជាតិទាំងពីរ។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ដោយរំលឹកពីទស្សនកិច្ចជាប្រវត្តិសាស្ត្រនៅបង់ក្លាដែស ក្នុងខែមិថុនា ឆ្នាំ២០១៤ សម្តេចតេជោ **នាយករដ្ឋមន្ត្រី** បានសម្តែងកិច្ចស្វាគមន៍ចំពោះទស្សនកិច្ចតបវិញរបស់ **លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា** ថាជា "ទស្សនកិច្ចប្រវត្តិសាស្ត្រ" និងបានកត់សម្គាល់ថា ទស្សនកិច្ចរបស់លោកជំទាវ នឹងធ្វើឲ្យទំនាក់ទំនងដ៏ល្អប្រសើរដែលមានស្រាប់រវាងប្រទេសជាមិត្តទាំងពីរឈានឡើងកាន់តែខ្ពស់ថែមទៀត។លោកជំទាវនាយករដ្ឋមន្ត្រី **សេក្ខ ហាស៊ីណា** បានចាត់ទុកកម្ពុជា ជា "មិត្តដ៏ជិតស្និទ្ធរបស់បង់ក្លាដែស និងជាដៃគូដ៏សំខាន់ក្នុងតំបន់អាស៊ាន"។ **នាយករដ្ឋមន្ត្រីទាំងពីរ** បានកត់សម្គាល់ដោយការពេញចិត្តផងដែរថា **កម្ពុជា** និង **បង់ក្លាដែស** បានអភិវឌ្ឍន៍ជាដៃគូដ៏រឹងមាំ និងផ្តល់ប្រយោជន៍ទៅវិញទៅមក ក្នុងកម្រិតទ្វេភាគី តំបន់ និងពហុភាគី ដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព សន្តិភាព និងសន្តិសុខនៅក្នុងតំបន់។

សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអបអរសាទរ លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា ចំពោះជោគជ័យដ៏អស្ចារ្យក្នុងវិស័យសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍន៍ប្រជាជន ដែលបង់ក្លាដែសសម្រេចបានក្នុងទសវត្សរ៍កន្លងទៅនេះ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់លោកជំទាវនាយករដ្ឋមន្ត្រី។ លោក**ជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា** បានកោតសរសើរសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំពោះការដែលរាជរដ្ឋាភិបាលកម្ពុជាបន្តសម្រេចបាននូវជោគជ័យ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ ឧស្សាហកម្មទេសចរណ៍រឹងមាំ និងបានធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពជីវិតរស់នៅរបស់ប្រជាជនកម្ពុជា។ លោកជំទាវ **នាយករដ្ឋមន្ត្រីបានអបអរសាទរ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ចំពោះជោគជ័យរបស់គណបក្សប្រជាជនកម្ពុជា នៅក្នុងការបោះឆ្នោតឃុំ-សង្កាត់ កាលពីខែមិថុនាកន្លងទៅ ដែលបានប្រព្រឹត្តទៅដោយរលូន សេរី និងយុត្តិធម៌ និងបានជូនពរសូមឲ្យទទួលបាននូវជោគជ័យដូចគ្នា ក្នុងការបោះឆ្នោតព្រឹទ្ធសភា នៅថ្ងៃទី២៥ ខែកុម្ភៈ និងការបោះឆ្នោតទូទៅ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨។ នាយករដ្ឋមន្ត្រីទាំងពីរ បានកត់សម្គាល់ដោយពេញចិត្ត ចំពោះជោគជ័យដែលទទួលបានការអបអរសាទរទូទាំងពិភពលោក ក្នុងការកាត់បន្ថយភាពក្រីក្រ នៅប្រទេសទាំងពីរក្នុងអំឡុងទសវត្សរ៍កន្លងមក និងការដែលប្រទេសទាំងពីរ កម្ពុជា និង **បង់ក្លាដែស** សម្រេចបានឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ក្នុងឆ្នាំ២០១៥។

នាយករដ្ឋមន្ត្រីទាំងពីរ បានគូសបញ្ជាក់លើតម្រូវការ និងអត្ថប្រយោជន៍នៃការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ជាទៀងទាត់ និងការប្រាស្រ័យទាក់ទងទ្វេភាគី ដែលនឹងផ្តល់នូវវិធី និងមធ្យោបាយ សម្រាប់ធ្វើការកែសម្រួលឡើងវិញនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ រវាងប្រទេសជាមិត្តទាំងពីរ។ ដោយរំលឹកពីការបង្កើត**គណៈកម្មការចម្រុះកម្ពុជា-បង់ក្លាដែស** នៅឆ្នាំ២០១៤ ដឹកនាំដោយរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរ ភាគីទាំងពីរ បានឯកភាពថា កិច្ចប្រជុំគណៈកម្មការចម្រុះលើកទីមួយ អាចប្រព្រឹត្តទៅក្នុងឆ្នាំ២០១៨ នៅទីក្រុង**ដាកា**។ នាយករដ្ឋមន្ត្រីទាំងពីរ បានសម្តែងការពេញចិត្តចំពោះការបង្កើតក្រុមមិត្តភាពសភា **កម្ពុជា-បង់ក្លាដែស** ក្នុងឆ្នាំ២០០៩ ហើយក៏បានអំពាវនាវឲ្យមានការផ្លាស់ប្តូរទស្សនកិច្ច និងកិច្ចសហប្រតិបត្តិការជាទៀងទាត់ រវាងសភានៃប្រទេសទាំងពីរផងដែរ។

ដោយគូសបញ្ជាក់អំពីពាណិជ្ជកម្មទ្វេភាគី រវាងប្រទេសទាំងពីរ ដែលបានបន្តកើនឡើងដល់ ១២% ក្នុងអំឡុងពេលពីរឆ្នាំចុងក្រោយនេះ នាយករដ្ឋមន្ត្រីទាំងពីរឯកភាពគ្នាថា ប្រទេសដែលកំពុងអភិវឌ្ឍន៍សេដ្ឋកិច្ចទាំងពីរចាំបាច់ត្រូវសម្រេចឲ្យបានពេញលេញថែមទៀតនូវសក្តានុពល ពាណិជ្ជកម្ម និងវិនិយោគរបស់ប្រទេសទាំងពីរ តាមរយៈការប្រើប្រាស់អត្ថប្រយោជន៍ប្រៀបធៀប និងលក្ខណៈបំពេញបន្ថែមឲ្យគ្នា។ ក្នុងបរិបទនេះ នាយករដ្ឋមន្ត្រីទាំងពីរបានកត់សម្គាល់ដោយពេញចិត្តចំពោះការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់

ស្តីពីពាណិជ្ជកម្មអង្ករ រវាងប្រទេសទាំងពីរកាលពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ដែលក្នុងនោះបង់ក្លាដែស ឯកភាពទិញអង្ករពីកម្ពុជារហូតដល់មួយលានតោន ក្រោមល័ក្ខខ័ណ្ឌដែលត្រូវព្រមព្រៀងគ្នា។ ក្នុងបរិបទនេះដែរ បង់ក្លាដែសសង្ឃឹមថាកម្ពុជានឹងពិចារណានាំចូលផលិតផលពីបង់ក្លាដែស មានដូចជា បាវក្រចៅគុណភាពល្អមិនប៉ះពាល់បរិស្ថាន១០០% សម្រាប់ផ្ទុកស្រូវអង្ករ ឱសថដែលមានការទទួលស្គាល់ទូទាំងពិភពលោក សម្ភារៈប្រើប្រាស់ធ្វើពីសេរ៉ាមិក ស្បែកក្រៀម ស្បែកសម្រេច ហើយកម្ពុជាក៏រំពឹងថាបង់ក្លាដែសនឹងពិចារណានាំចូលផលិតផលកសិកម្មរបស់កម្ពុជា មានដូចជា ពោត ម្រេច ដំឡូងក្រៀម និងគ្រាប់ស្វាយចន្ទី។

នាយករដ្ឋមន្ត្រីទាំងពីរ ស្វាគមន៍ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ស្តីពីម៉ូដែលសម្រាប់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នចំណុះក្រុមប្រឹក្សាពាណិជ្ជកម្មចម្រុះ រវាងក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរ និងបានស្នើឲ្យក្រុមប្រឹក្សាពាណិជ្ជកម្មចម្រុះកម្ពុជា-បង់ក្លាដែស (JTC) ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរ ដែលទើបបានបង្កើតឡើងធ្វើការកោះប្រជុំលើកដំបូងឲ្យបានឆាប់ នៅឆ្នាំ២០១៨ ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ នាយករដ្ឋមន្ត្រីទាំងពីរ បានស្វាគមន៍ការប្រព្រឹត្តទៅនៃ "សន្និសីទពាណិជ្ជកម្ម និងការវិនិយោគបង់ក្លាដែស" លើកដំបូង ដែលបានរៀបចំឡើងនៅភ្នំពេញ ពីខែមករា ឆ្នាំ២០១៧ ក្រោមកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្មកម្ពុជា និងលើកទឹកចិត្តឲ្យភាគីទាំងពីររៀបចំសន្និសីទ និងពិព័រណ៍ពាណិជ្ជកម្មបែបនេះបន្ថែមទៀត ដើម្បីបង្កើនបរិមាណ និងពង្រីកវិសាលភាពពាណិជ្ជកម្មទ្វេភាគី។ នាយករដ្ឋមន្ត្រីទាំងពីរ បានប្រគល់ភារកិច្ចជូនស្ថាប័នពាក់ព័ន្ធនៃប្រទេសទាំងពីរឲ្យពិនិត្យរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មី ជំនួសកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាក្នុងឆ្នាំ២០០៦ ដើម្បីឆ្លុះបញ្ចាំងពីការអភិវឌ្ឍន៍ និងស្ថានភាពបច្ចុប្បន្ននៃពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងបង់ក្លាដែស។

នាយករដ្ឋមន្ត្រីទាំងពីរ បានកត់សម្គាល់ដោយការពេញចិត្ត ចំពោះការរីកលូតលាស់យ៉ាងឆាប់រហ័ស នៃវិស័យនាំចេញសំលៀកបំពាក់របស់បង់ក្លាដែស និង កម្ពុជា ហើយបានសង្កត់ធ្ងន់អំពីតម្រូវការឲ្យប្រទេសទាំងពីររួមសហការគ្នាដើម្បីធានាឲ្យផលិតផលសំលៀកបំពាក់របស់ប្រទេសទាំងពីរបានចូលទៅកាន់ទីផ្សារកាន់តែធំនៅក្នុងប្រទេសអភិវឌ្ឍន៍។

សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តែងការពេញចិត្តចំពោះការវិនិយោគរបស់បង់ក្លាដែសនៅកម្ពុជា ជាពិសេសវិស័យសំលៀកបំពាក់ និងបានអំពាវនាវឲ្យមានការវិនិយោគថ្មីទៀតពីបង់ក្លាដែស រួមទាំងក្នុងវិស័យកសិកម្ម (គ្រាប់ធញ្ញជាតិ, ការចិញ្ចឹមសត្វ, កៅស៊ូ, ព្រៃឈើ, ជលផល ត្រីកែច្នៃ និងការដាំដំណាំតាមកិច្ចសន្យា) ផលិតផលស្បែក និងផ្នែកព័ត៌មានវិទ្យា។ ថ្លែងអំពីគោលការណ៍វិនិយោគសេរី និងការលើកទឹកចិត្តផ្តល់ជូនវិនិយោគិនបរទេសដោយរដ្ឋាភិបាលបង់ក្លាដែស លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា ក៏បានអញ្ជើញវិនិយោគិនពីកម្ពុជាឲ្យទៅប្រទេសបង់ក្លាដែសផងដែរ ពិសេសក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងសេវាកម្ម។ ហេតុដូច្នេះ នាយករដ្ឋមន្ត្រីទាំងពីរ បានស្វាគមន៍ការចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការស្ថាប័នលើកិច្ចការពាក់ព័ន្ធនឹងការជម្រុញវិនិយោគរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងអាជ្ញាធរអភិវឌ្ឍវិនិយោគបង់ក្លាដែស (Bangladesh Investment Development Authority / BIDA)។ ក្នុងន័យនេះដែរ នាយករដ្ឋមន្ត្រីទាំងពីរក៏បានសង្កត់ធ្ងន់អំពីតម្រូវការត្រូវពង្រីកការប្រាស្រ័យទាក់ទងគ្នាឲ្យកាន់តែទូលំទូលាយរវាងវិស័យឯកជន សភាពាណិជ្ជកម្ម និងសហគមន៍ធុរកិច្ចនៃប្រទេសទាំងពីរ សំដៅលើកស្ទួយការតភ្ជាប់ពាណិជ្ជកម្ម និងធុរកិច្ច។ នៅក្នុងបរិបទនេះ នាយករដ្ឋមន្ត្រីទាំងពីរក៏បានស្វាគមន៍ការចុះ

ហត្ថលេខាលើ កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការរវាងសភាពាណិជ្ជកម្មកម្ពុជា (CCC) និងសហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មបង់ក្លាដែស (Federation of Bangladesh Chambers of Commerce and Industry / FBCCI)។

ដោយរំលឹកពីអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេសក្នុងវិស័យកសិកម្ម ដែលបានចុះហត្ថលេខារវាងប្រទេសទាំងពីរ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ នាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍ការបង្កើតក្រុមការងារកសិកម្មចម្រុះ (JAWG) រវាងរដ្ឋាភិបាលទាំងពីរ និងបានសម្រេចថាការប្រជុំលើកទីមួយ នៃក្រុមការងារកសិកម្មចម្រុះនោះនឹងត្រូវធ្វើនៅទីក្រុងដាកា ក្នុងអំឡុងត្រីមាសទីពីរ ឆ្នាំ២០១៨។ ដោយសង្កត់ធ្ងន់ពីការចាំបាច់ត្រូវធ្វើឲ្យកាន់តែស៊ីជម្រៅនូវសហប្រតិបត្តិការបច្ចេកទេស រវាងប្រទេសនាំចេញត្រីទាំងពីរ នាយករដ្ឋមន្ត្រីទាំងពីរ បានស្វាគមន៍ការចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការវិស័យវារីវប្បកម្ម និងនេសាទរវាងរដ្ឋាភិបាលទាំងពីរ។

នាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស។

លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា បានកោតសរសើរ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលសម្រេចជោគជ័យដ៏វិសេសវិសាល ក្នុងការជម្រុញឲ្យមានការរីកលូតលាស់ផ្នែកឧស្សាហកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច ហើយបានសម្តែងក្តីសង្ឃឹមថានឹងមានកិច្ចសហការ និងកិច្ចសហប្រតិបត្តិការជាមួយគ្នាកាន់តែច្រើនក្នុងវិស័យទេសចរណ៍។ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកោតសរសើរ លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា ដែលបានដាក់ចេញនូវចក្ខុវិស័យឌីជីថលបង់ក្លាដែស និងសម្រេចបានការរីកចម្រើនដ៏អស្ចារ្យក្នុងដំណើរការធ្វើឌីជីថលសកលភាវូបនីយកម្ម (Digitalization)ប្រទេសបង់ក្លាដែស។ ទាក់ទងនឹងបញ្ហានេះ នាយករដ្ឋមន្ត្រីទាំងពីរ បានគូសបញ្ជាក់ពីការចាំបាច់ត្រូវបង្កើនការតភ្ជាប់វិស័យព័ត៌មានវិទ្យាឲ្យបានទូលំទូលាយរវាងប្រទេសទាំងពីរ និងបានស្វាគមន៍ការចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ និងកិច្ចសហប្រតិបត្តិការក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) រវាងរដ្ឋាភិបាលទាំងពីរ។ ដើម្បីបង្កើនការតភ្ជាប់ផ្លូវអាកាស និងជម្រុញវិស័យទេសចរណ៍រវាងប្រទេសទាំងពីរ នាយករដ្ឋមន្ត្រីទាំងពីរ បានគូសបញ្ជាក់អំពីការចាំបាច់ត្រូវចុះហត្ថលេខាលើ កិច្ចព្រមព្រៀងសេវាកម្មផ្លូវអាកាសរវាងប្រទេសទាំងពីរឲ្យបានឆាប់ ដើម្បីបើកការតភ្ជាប់ផ្លូវអាកាសរវាងរាជធានី និងរដ្ឋធានីរបស់ប្រទេសទាំងពីរ។

ដោយក្តីគោរពដល់ប្រវត្តិសាស្ត្រប្រហាក់ប្រហែលគ្នា ក្នុងការតស៊ូរំដោះជាតិ និងទុក្ខវេទនាដែលប្រជាជនកម្ពុជា និងបង់ក្លាដែសបានទទួលរងក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៅកម្ពុជា និងសង្គ្រាមរំដោះជាតិនៅបង់ក្លាដែស នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងស្មារតីសាមគ្គីភាពថានឹងធ្វើកិច្ចសហការជាមួយគ្នា ដើម្បីថែរក្សាទុកនូវដំណែលនៃប្រវត្តិសាស្ត្រសង្គ្រាមជាតិ វីរជនសង្គ្រាម និងបូជនីយស្ថានសង្គ្រាម និងសារមន្ទីរប្រល័យពូជសាសន៍របស់ប្រទេសទាំងពីរ និងបង្កើនការយល់ដឹងឲ្យកាន់តែទូលំទូលាយដល់មនុស្សជំនាន់ក្រោយៗទៀត។ ក្នុងបរិបទនេះ នាយករដ្ឋមន្ត្រីទាំងពីរ ស្វាគមន៍ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីសហប្រតិបត្តិការក្នុងការអភិរក្សប្រវត្តិសាស្ត្រសង្គ្រាម បូជនីយស្ថានសង្គ្រាម និងកេរដំណែលសង្គ្រាម រវាងរដ្ឋាភិបាលទាំងពីរ។

នាយករដ្ឋមន្ត្រីទាំងពីរក៏បានសង្កត់ធ្ងន់អំពីការចាំបាច់ត្រូវបង្កើនកិច្ចសហប្រតិបត្តិការក្នុងវិស័យវប្បធម៌ សាសនា
និងអប់រំ តាមរយៈកម្មវិធីផ្លាស់ប្តូរផ្នែកវប្បធម៌ សាសនា និងអប់រំ។

ដោយដៅបញ្ជាក់អំពីសេចក្តីប្រាថ្នាសម្រេច **គោលដៅអភិវឌ្ឍដោយចីរភាពជាតិ** របស់ប្រទេសទាំងពីរ
និង រំលឹកដល់ការប្តេជ្ញាកំរិតនយោបាយរបស់រដ្ឋាភិបាលទាំងពីរក្នុងការសម្រេចគោលដៅអភិវឌ្ឍដោយចីរភាព
(SDGs) ត្រឹមឆ្នាំ២០៣០ ក្រោមការគាំទ្រពីអង្គការសហប្រជាជាតិ នាយករដ្ឋមន្ត្រីទាំងពីរបានអះអាងជាថ្មីនូវ
សាមគ្គីភាពក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការចែករំលែកឧត្តមានុវត្តន៍ ក្នុងការអនុវត្តគោលដៅអភិវឌ្ឍដោយ
ចីរភាព ថ្នាក់ជាតិរវាងប្រទេសទាំងពីរ។ ក្នុងបរិបទនេះ នាយករដ្ឋមន្ត្រីទាំងពីរ បានស្វាគមន៍ការចុះហត្ថលេខា
លើ អនុស្សរណៈនៃការយោគយល់គ្នាស្តីពី “កិច្ចសហប្រតិបត្តិការ និងកិច្ចសហការលើបញ្ហាពាក់ព័ន្ធក្នុងការអនុវត្ត
គោលដៅអភិវឌ្ឍន៍ដោយចីរភាពរហូតដល់ឆ្នាំ២០៣០” រវាងរដ្ឋាភិបាលទាំងពីរ ហើយរំពឹងថានឹងមានកិច្ចសហការ
ជាដៃគូនឹងគ្នានាពេលអនាគត ដើម្បីផ្សព្វផ្សាយបង្ហាញពីជោគជ័យនៃការអភិវឌ្ឍដោយចីរភាពរបស់ប្រទេសទាំង
ពីរ នៅឯវេទិកាអង្គការសហប្រជាជាតិ និងវេទិកាពហុភាគីដទៃទៀត។

លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា បានអបអរសាទរ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន
ចំពោះការដែលកម្ពុជាត្រូវបានជ្រើសរើសជាឯកច្ឆន្ទឲ្យធ្វើជា អ្នកសម្របសម្រួលក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ក្នុង
ក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក កាលពីខែកុម្ភៈឆ្នាំនេះ បន្តពីប្រទេសបង់ក្លាដែស។ ជាមួយនឹងការ
សម្តែងជំនឿជឿជាក់ថាកម្ពុជា នឹងលើកកម្ពស់ប្រកបដោយខ្លឹមសារជាក់ស្តែង ហើយនិងការពារផលប្រយោជន៍
របស់ប្រទេសអភិវឌ្ឍន៍តិចតួចនៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១១របស់អង្គការពាណិជ្ជកម្មពិភពលោក នៅ
ក្រុង Buenos Aires ប្រទេសអាហ្សង់ទីន លោកជំទាវនាយករដ្ឋមន្ត្រីបានធានាអះអាងថាបង់ក្លាដែសនឹងផ្តល់
ការគាំទ្រ និងកិច្ចសហប្រតិបត្តិការពេញទំហឹងចំពោះកម្ពុជា ក្នុងអំឡុងអាណត្តិកម្ពុជាជាអ្នកសម្របសម្រួលក្រុម
ប្រទេសអភិវឌ្ឍន៍តិចតួច។

ដោយគូសបញ្ជាក់អំពីភាពជាដៃគូរឹងមាំរបស់បង់ក្លាដែសជាមួយប្រទេសសមាជិកអាស៊ាន រួមទាំង
កម្ពុជាផង លើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងសន្តិសុខក្នុងតំបន់ ក្នុងក្របខ័ណ្ឌវេទិកាតំបន់អាស៊ាន (ARF)
និង កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា បានអះអាងជាថ្មីពីការប្តេជ្ញា
យ៉ាងមុតមាំរបស់រដ្ឋាភិបាលបង់ក្លាដែស ក្នុងការជម្រុញសន្ទុះទំនាក់ទំនងវិស័យសេដ្ឋកិច្ច និងការតភ្ជាប់ជាមួយ
អាស៊ាន។ ក្នុងន័យនេះ លោកជំទាវនាយករដ្ឋមន្ត្រី បានសំណូមពរការគាំទ្ររបស់កម្ពុជាចំពោះសំណើរបស់
បង់ក្លាដែសសុំធ្វើជាដៃគូសន្ទនាតាមផ្នែករបស់អាស៊ាន។ លោកជំទាវនាយករដ្ឋមន្ត្រីក៏បានស្នើសុំការគាំទ្រផងដែរ
ចំពោះបំណងរបស់ប្រទេសបង់ក្លាដែស ចង់ចូលរួមជាសមាជិកវេទិកាសហប្រតិបត្តិការមេគង្គ-គង្គា ក្នុងនាមជា
ប្រទេសដែលស្ថិតលើអាងទន្លេគង្គាផងដែរ។ សម្តេចតេជោនាយករដ្ឋមន្ត្រីបានស្វាគមន៍កិច្ចសហប្រតិបត្តិការ និង
ទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់បង់ក្លាដែសជាមួយរដ្ឋសមាជិកអាស៊ាន។ សម្តេចតេជោបានធានាការគាំទ្រពេញ
ទំហឹងរបស់រដ្ឋាភិបាលកម្ពុជាឲ្យមានការឯកភាពតាមកុងសង់ស៊ីសអាស៊ាន ចំពោះបំណងរបស់ប្រទេសបង់ក្លាដែស
ចង់ក្លាយជាដៃគូតាមវិស័យរបស់អាស៊ាន។

លោកជំទាវនាយករដ្ឋមន្ត្រី សេក្ខ ហាស៊ីណា បានជម្រាបថា មានប្រជាជនរាប់រយពាន់នាក់បានខ្ចាត់
ព្រាត់ពីលំនៅដ្ឋាននៅរដ្ឋរ៉ាក់ខាញ ប្រទេសមីយ៉ាន់ម៉ា មកជ្រកកោននៅប្រទេសបង់ក្លាដែសក្នុងអំឡុងពេល៣ខែ
កន្លងទៅនេះ។ លោកជំទាវនាយករដ្ឋមន្ត្រី បានស្នើសុំកម្ពុជាគាំទ្រឲ្យមានការឈានទៅរកដំណោះស្រាយយូរ
អង្វែងចំពោះវិបត្តិនេះ។ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកោតសរសើរកាយវិការមនុស្សធម៌ដ៏

វិសេសវិសាលរបស់លោកជំទាវនាយករដ្ឋមន្ត្រី **សេត្ថា ហាស៊ីណា** ក្នុងការទទួលប្រជាជនដែលខ្វាត់ព្រាត់ពីលំនៅដ្ឋានទាំងនេះ។ នាយករដ្ឋមន្ត្រីទាំងពីរ បានអំពាវនាវឲ្យមានការសន្ទនាដោយសន្តិវិធី និងកិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីពាក់ព័ន្ធដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាពយូរអង្វែងក្នុងតំបន់។

ដោយរំលឹកពីការចូលរួមយ៉ាងសកម្មរបស់**បង់ក្លាដែស និងកម្ពុជា** នៅក្នុងកិច្ចប្រជុំកំពូលស្តីពីកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ (ACD) នៅទីក្រុងបាងកក នាយករដ្ឋមន្ត្រីទាំងពីរ បានអះអាងជាថ្មីពីការប្តេជ្ញា ខិតខំជម្រុញឲ្យមានការតភ្ជាប់ និងភាពជាដៃគូសេដ្ឋកិច្ច-សង្គមកាន់តែស៊ីជម្រៅ ក្រោមក្របខ័ណ្ឌ ACD និងបានសម្រេចសហការរៀបចំព្រឹត្តិការណ៍រួមគ្នាក្នុងឋានៈជាសហប្រទេសនាំមុខ (Co-Prime movers) លើបញ្ហាដែលប្រទាក់ក្រឡាគ្នា ដូចជា វប្បធម៌ សាសនានិងទេសចរណ៍ ការតភ្ជាប់ បញ្ហាទឹក សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ។

ក្នុងឱកាសទស្សនកិច្ចនេះ នាយករដ្ឋមន្ត្រីទាំងពីរបានស្វាគមន៍ និងធ្វើជាសាក្សីក្នុងការចុះហត្ថលេខាលើឯកសារឧបករណ៍ទ្វេភាគីរវាងប្រទេសទាំងពីរដូចខាងក្រោម ៖

i. អនុស្សារណៈនៃការយោគយល់គ្នាស្តីកិច្ចសហប្រតិបត្តិការ និង កិច្ចសហការលើបញ្ហាពាក់ព័ន្ធក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពរហូតដល់ឆ្នាំ២០៣០ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

ii. អនុស្សារណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

iii. អនុស្សារណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

iv. អនុស្សារណៈនៃការយោគយល់គ្នាស្តីពីម៉ូដែលសម្រាប់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នចំណុះក្រុមប្រឹក្សាពាណិជ្ជកម្មចម្រុះ រវាងក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

v. អនុស្សារណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការស្ថាប័ន លើកិច្ចការពាក់ព័ន្ធនឹងការជម្រុញវិនិយោគរវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា និងអាជ្ញាធរអភិវឌ្ឍន៍ការវិនិយោគបង់ក្លាដែស នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

vi. អនុស្សារណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស

vii. អនុស្សារណៈនៃការយោគយល់គ្នារវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងនេសាទ និងបសុសត្វ នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពីកិច្ចសហប្រតិបត្តិការវិស័យវារីវប្បកម្ម និងនេសាទ

viii. អនុស្សារណៈនៃការយោគយល់គ្នារវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតបង់ក្លាដែសស្តីពីសហប្រតិបត្តិការក្នុងការអភិរក្សប្រវត្តិសាស្ត្រសង្គ្រាមបូជនីយស្ថានសង្គ្រាម និងកេរដំណែលសង្គ្រាម

ix. អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសិក្សាស្រាវជ្រាវ រវាង រាជបណ្ឌិត្យសភាកម្ពុជា និងវិទ្យាស្ថានសិក្សាអន្តរជាតិ និងយុទ្ធសាស្ត្របង់ក្លាដែស

x. កិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការរវាង សភាពាណិជ្ជកម្មកម្ពុជា និងសហព័ន្ធសភាពាណិជ្ជកម្ម និងឧស្សាហកម្មបង់ក្លាដែស

លោកជំទាវនាយករដ្ឋមន្ត្រី **សេក្ខ ហាសុីណា** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចតេជោ **នាយករដ្ឋមន្ត្រី ហ៊ុន សែន** និងប្រជាជនកម្ពុជាដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅនិងបានផ្តល់បដិសណ្ឋារកិច្ចយ៉ាងរាក់ទាក់ជូនចំពោះលោកជំទាវនាយករដ្ឋមន្ត្រី និងប្រតិភូអមដំណើរ ក្នុងអំឡុងពេលនៃទស្សនកិច្ច។ **លោកជំទាវ** បានសុំអញ្ជើញសម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅបំពេញទស្សនកិច្ចវិញនៅបង់ក្លាដែសក្នុងពេលវេលាសមស្របរបស់ភាគីទាំងពីរនាពេលអនាគត។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ហ៊ុន សែន បានថ្លែងអំណរគុណ និងទទួលយកនូវការអញ្ជើញរបស់**លោកជំទាវ**នាយករដ្ឋមន្ត្រី ហើយបានសន្យាទៅបំពេញទស្សនកិច្ចតបវិញនាពេលអនាគត ដើម្បីពង្រឹងថែមទៀតនូវមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ភ្នំពេញ ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៧